## គ្រូបង្រៀនសាលាបឋមសិក្សាវិលត្រឡប់ទៅសាលារៀនវិញ-សិស្សថ្នាក់អន្តរមត្តេយ្យ-៥ TK-5 ចាប់ផ្តើមថ្ងៃច័ន្ទ

សហគមន៍សាលារៀនក្នុងតំបន់ឡុងប៊ីចជាទីមេត្រី,

នៅក្នុងសប្តាហ៍នេះ យើងអបអរដល់ការវិលត្រឡប់ទៅសាលារៀនវិញដល់បុគ្គលិកពីថ្នាក់អន្តរមត្តេយ្យ-ទី៥។ ចំពោះគ្រូបង្រៀនជាច្រើននាក់ដែលបានធ្វើការពីផ្ទះ ពួកគេបានចូលរួមជាមួយបុគ្គលិកសាលាបឋមសិក្សានិងសាលាកម្រិតថ្នាក់មត្តេយ្យ-ទី៨ K-8 ដើម្បីរៀបចំត្រៀមបំរុងសម្រាប់សិស្សជាច្រើននាក់ដែលនឹងវិលត្រឡប់ទៅរៀនផ្ទាល់នៅសាលាវិញដែលចាប់ផ្តើមនៅថ្ងៃច័ន្ទ។ ក្នុងសប្តាហ៍នេះ ខ្ញុំមានសេចក្តីរីករាយដោយបានទៅដើរទស្សនា សាលារៀននានាដើម្បីមើលការរៀបចំបំរុងដែលសាលារៀនបានកំពុងធ្វើសម្រាប់សិស្ស ហើយនិងបានស្តាប់ការគាំទ្រជាបន្ត សម្រាប់សិស្សដែលបន្តរៀនតាមអនឡាញ។

ការវិលត្រឡប់ទៅរៀនផ្ទាល់នៅសាលានេះនឹងមានការឆែកពិនិត្យអរោគសញ្ញាដើម្បីរកមើលរករោគកូវីឌ សម្រាប់បុគ្គលិកនិងសិស្សទាំងអស់។ នីតិវិធីនេះបានចាប់ផ្តើមធ្វើឡើងកាលពីថ្ងៃសៅរ៍មុន ហើយតាំងពីពេលនោះមកមានសិស្សនិងបុគ្គលិករាប់ពាន់នាក់បានទទួលការឆែកពិនិត្យមើល។ ខ្ញុំមានការពេញចិត្តយ៉ាងខ្លាំងជាមួយការធ្វើការរួមដៃគ្នា រវៀងបុគ្គលិកនៅក្នុងក្រសួងអប់រំឡុងប៊ីចទាំងមូល គឺមានរួមទាំងនាយកដ្ឋានពាណិជ្ជកម្ម នាយកដ្ឋានផ្តល់ការគាំទ្រដល់ការសិក្សា និងការិយាល័យសាលារៀន។ ក្រុម LBUSD កំពុងធ្វើការរួមដៃគ្នាលើគ្រប់ផ្នែកទាំងអស់ ដើម្បីបញ្ជាក់ថាការបើកសាលារៀននេះមានសុវត្ថិភាពល្អ។

ករណីអត្រាកូវីឌ-១៩នៅក្នុងខោនធីឡូសអ៊ិនជើលេសគឺ 3.8 លើ 100,000 នាក់នៅក្នុងសប្តាហ៍នេះ ដែលជាការបន្តចុះថយក្នុងរយៈពេលប៉ុន្មានសប្តាហ៍កន្លងទៅនេះ។ ដំណឹងល្អពីសុខភាពសហគមន៍នេះនឹងអនុញ្ញាតឱ្យ ក្រសួងអប់រំតំបន់ឡុងប៊ីចអនុវត្តគម្រោងបើកសាលារៀនដែលបានគ្រោងមក ដែលមានរួមទាំងគម្រោងផ្តល់ការបង្ហាត់បង្រៀនផ្ទាល់តាមកាលវិភាគហាយប្រ៊ិឌសម្រាប់សិស្សសាលាអនុវិទ្យាល័យនិងវិទ្យាល័យ ដូចដែលបានប្រកាសកន្លងមកសម្រាប់ខែមេសា។ ខណៈដែលពាណិជ្ជកម្មនិងសេវាកម្មផ្សេងៗបានចាប់ផ្តើមឡើងវិញជាបន្តបន្ទាប់នៅក្នុងតំបន់យើង យើងសូមលើកទឹកចិត្តដល់បុគ្គលិកនិងសមាជិកក្នុងសហគមន៍ឱ្យបន្តប្រុងប្រយ័ត្នហើយអនុវត្តតាមវិធីការសុខភាពនិងសុវត្ថិភាពទាំងអស់។ នេះគឺរួមទាំងការពាក់ម៉ាស រក្សាគម្លាតពីគ្នា និងលាងសម្អាតដៃ។

នៅក្នុងរយៈពេលពីរបីថ្ងៃកន្លងនេះ យើងបានរៀបចំបំរុងសម្រាប់សិស្សប្រមាណជា 14,000 នាក់ដែលនឹងវិលត្រឡប់ទៅរៀនផ្ទាល់នៅសាលា។ យើងយល់ដឹងថារបៀបរបបថ្មីនិងកាលវិភាគថ្មីនឹងតម្រូវឱ្យអ្នករាល់គ្នាមានភាពបត់បែននឹងជួយគ្នាទៅវិញទៅមកនៅក្នុងរយៈពេលនៃអន្តរកម្មនេះ។ យើងបានលើកទឹកចិត្តដល់ទាំងមនុស្សពេញវ័យនិងសិស្សឱ្យថែទាំដល់អារម្មណ៍របស់គាត់និងអនុញ្ញាតឱ្យពួកគាត់បញ្ចេញនិងគិតគូដល់អារម្មណ៍របស់ពួកគាត់។ ជាមនុស្សពេញវ័យនៅក្នុងសហគមន៍ យើងសូមលើកទឹកចិត្តឱ្យលោកអ្នកស្វែងរកជំនួយសម្រាប់ខ្លួនឯងនិងសម្រាប់កូនបើអ្នកត្រូវការជំនួយនៅក្នុងពេលអន្តរកម្មនេះ។

## សាលាអនុវិទ្យាល័យនិងសាលាវិទ្យាល័យ

យើងមានសេចក្តីរំពឹងរង់ចាំស្វាគមន៍គ្រូបង្រៀននិងសិស្សសាលាអនុវិទ្យាល័យនិងវិទ្យាល័យយើងនៅខែក្រោយនេះ។ យើងត្រូវបានសួរពីសំណាក់សមាជិកបុគ្គលិកនៅក្នុងសហគមន៍ថាហេតុអ្វីបានជាយើងមិនឱ្យសិស្សសាលា វិទ្យាល័យវិលត្រឡប់ចូលរៀនវិញឱ្យបានឆាប់ជាងការគ្រោងនេះ យោងទៅតាមស្ថានភាពសុខភាពនៅក្នុងសហគមន៍។ ផ្លូវមួយដែលងាយជាងគេដែលខ្ញុំអាចពន្យល់ពីមូលហេតុគឺថា វាចាំបាច់ត្រូវមានសហការគ្នាក្នុងទូទាំង ក្រសួងអប់រំ LBUSD –

រួមទាំងបុគ្គលិកផ្នែកដឹកជញ្ជូន ផ្នែកធ្វើឱ្យដំណើរការ ផ្នែកបោសសម្អាតថែអនាម័យ ផ្នែកគ្រប់គ្រងនៅសាលា គ្រូបង្រៀននិងបុគ្គលិកជំនួយនៅសាលា ដើម្បីបញ្ជាក់ឱ្យការវិលត្រឡប់ទៅសាលារៀនមានសុវត្ថិភាពល្អ។ នៅពេលដែលយើងបើកសាលាឡើងវិញ គឺយើងមិនចង់បិទវិញទេ។ ដោយមានសិស្ស 70,000 នៅ ក្នុងក្រសួងអប់រំ យើងបានបង្កើតការបើកសាលាជាអន្លើៗ ដើម្បីបញ្ជាក់ឱ្យមានសុវត្ថិភាព ហើយយើងកំពុងអនុវត្ត ទៅដូចតាមតារាងវេលាដែលគ្រោងមក ក្នុងការធ្វើឱ្យចប់សព្វគ្រប់នូវការបើកជាអន្លើនេះក្នុងចន្លោះថ្ងៃទី២៩មីនានិងទី២៦ខែ មេសា។ សាលាវិទ្យាល័យបានទទួលការអនុញ្ញាតឱ្យមានសិស្សនៅសាលាសម្រាប់ការប្រជុំក្លឹប ហាត់កីឡា និង សកម្មភាពផ្សេងៗទៀតជាច្រើន។ យើងរំពឹងថាសកម្មភាពទាំងនេះនឹងកើនឡើងរវៀងពីឥឡូវនេះទៅដល់ថ្ងៃទី២៦មេសា។

នៅដើមសប្តាហ៍នេះ មន្ត្រីសុខភាពក្នុងប្រទេសនិងក្នុងតំបន់បានកែផ្លាស់ប្តូរការណែនាំសម្រាប់ដាក់គម្លាតគ្នានូវតុសិស្សនៅក្នុងថ្នាក់រៀន ពី៦ហ្វីទទៅនៅត្រឹម៣ហ្វីទ។ ខណៈដែលការផ្លាស់ប្តូរនេះផ្តល់មកនូវភាពបត់បែនដល់យើង យើងពុំមានផ្លាស់ប្តូរគម្រោងរបស់យើងសម្រាប់បច្ចុប្បន្ននេះទេ។ ថ្នាក់រៀនរបស់យើងត្រូវបានរៀបចំរួចហើយ ហើយវិធីការរបស់យើងក៏ត្រូវបានដាក់ប្រតិបត្តិដែរ។

## ឆ្នាំសិក្សាឆ្នាំក្រោយ

នៅពេលដែលក្រុមបុគ្គលិកសាលារៀនរបស់យើងធ្វើការយ៉ាងឧស្សាហ៍ព្យាយាមដើម្បីធានាបាននូវកម្មវិធីបង្ហាត់បង្រៀនដែលអាចធ្វើទៅបានល្អបំផុតសម្រាប់និស្សិតដែលកំពុងវិលត្រឡប់ទៅសាលារៀននិងសម្រាប់អ្នកដែលនឹងបន្តការសិក្សាតាមអនឡាញ យើងក៏បន្តរៀបចំផែនការដោយក្តីរំភើបសម្រាប់ឆ្នាំសិក្សា ២០២១-២២ ដែរ។ ជាមួយនឹងការដាក់អនុវត្តនូវគោលការណ៍ណែនាំថ្មី យើងទន្ទឹងរង់ចាំនិស្សិតទាំងអស់ដែលចង់វិលត្រឡប់ទៅរកការបង្រៀនដោយផ្ទាល់សម្រាប់កម្មវិធីពេញមួយថ្ងៃ។ យើងនឹងបន្តពិចារណាឡើងវិញនូវទិដ្ឋភាពជាច្រើននៃបទពិសោធន៍របស់សិស្សរបស់យើងខណៈពេលដែលកំពុងរៀបចំផែនការអ្វីដែលសិស្សភាគច្រើននឹងពិពណ៌នាថាជាបទពិសោធន៍នៅសាលាធម្មតា។ ដូចដែលខ្ញុំបានចែករំលែកពីមុនយើងក៏នឹងចាប់ផ្តើមជម្រើសរៀនតាមអនឡាញថ្មីមួយសម្រាប់គ្រួសារដែលចង់បានជម្រើសនោះសម្រាប់គ្រួសាររបស់ពួកគេ។

ឆ្នាំកន្លងផុតទៅគឺជាពេលវេលាដ៏លំបាកនៃការរៀននិងការឡើងចុះជាច្រើន។ យើងមិនរំពឹងថានិទាឃរដូវនេះនឹងមកដោយគ្មានឧបសគ្គទេ។ អ្វីដែលខ្ញុំដឹងច្បាស់គឺគ្រួសារ LBUSD មានភាពរឹងមាំហើយនឹងបន្តប្រឈមមុខនឹងឧបសគ្គនីមួយៗជាមួយគ្នា។ សូមអរគុណដែលបានក្លាយជាសហគមន៍ដ៏អស្ចារ្យនិងដែលបានបង្ហាញការគាំទ្រជាគំរូសម្រាប់ឧត្តមភាពនិងសមធម៌នៅ LBUSD ។

យើងនឹងឈរជាមួយគ្នារហូតនៅក្នុងនិទាឃរដូវនិងទៅអនាគត។

ដោយក្តីគោរព

Jill

Jill Baker, Ed. D.
Superintendent of Schools
អគ្គនាយកនៃសាលារៀន